**ប្រការ ៣** : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬបង្កអោយមានការប៉ះ ពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញ ដោយគ្មានសំណងឡើយ ។

**ប្រការ ៤** : ប្រកាសលេខ ២៣២ ផក.ប្រក ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៩៤ ត្រូវបានចាត់ទុកជានិរាករណ៍ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**ពុំ សុធីរៈ**

* * *

# ៣— ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## ១—សេចក្តីសំរេច

រាជធានីភ្នំពេញ , ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

**សេចក្តីសំរេចលេខ ០៤២/៩៦ ពម.សសរ**

**ស្តីពីការបង្កើតគណៈកម្មាធិការ កំណត់មុខលេខគុណៈសម្បត្តិ វាយតំលៃនិងប្រគល់កិច្ចសន្យា ( PEAC )**

* * *

– បានឃើញអនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩៩៥ ស្តីពីការគ្រប់គ្រងលទ្ធកម្មសាធារណៈ

– បានឃើញសារាចរណែនាំលេខ ០០៦ សណន.សហវ.លស ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការអនុវត្តនីតិវិធាន និងបទបញ្ញត្តិ ក្នុងការគ្រប់គ្រងលទ្ធកម្មសាធារណៈ

– បានឃើញសេចក្តីប្រកាសលេខ ៣៦៣ សហវ.លស.ប្រក ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការចុះឈ្មោះក្នុងបញ្ជីអ្នកទទួលការសាងសង់

- បានឃើញសេចក្ដីប្រកាសលេខ ៣១៩ កហមវ.ប្រក ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ១៩៩៥ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្ដីពីការអនុវត្តវិធានការនិងបទបញ្ញាតិក្នុងការគ្រប់គ្រងលទ្ធកម្មសាធារណៈ

**សំរេច**

**ប្រការ ១** : បង្កើតគណៈកម្មាធិការកំណត់បុរេលក្ខសម្បត្តិ វាយតំលៃ និងប្រគល់កិច្ចសន្យា (PEAC)

| | | |
|---|---|---|
| ១-ឯកឧត្ដម **អ៊ុំ ឆាស៊ាម** | អនុរដ្ឋលេខាធិការ | ប្រធាន |
| ២-លោក **សេង ម៉ាលីស** | អគ្គនាយករង | សមាជិក |
| ៣-លោក **សែន សំណាង** | អគ្គាធិការរង | សមាជិក |
| ៤-លោក **សេង នីន** | ប្រធានអង្គភាពលទ្ធកម្ម | ជាលេខាធិការ |

៥- សាម៉ីអង្គភាពពាក់ព័ន្ធ ចូលរួមស្រាយបំភ្លឺ

**ប្រការ ២** : ឯកឧត្ដម អស់លោក ដូចមានឈ្មោះក្នុងប្រការ ១ ត្រូវទទួលអនុវត្តតាមដីការសំរេច ។

**ប្រការ ៣** : ដីកាសំរេចនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី
ហត្ថលេខា និង ត្រា
**អៀង មូលី**

* * *

## ២—ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

**ប្រកាសលេខ ០៤៧/៩៦ ពម.ប្រក**

**អនុញ្ញាតអោយលោក សេង សាយ**

**បើកអាជីវកម្មរោងពុម្ពឈ្មោះ « សាន ឃាក់ »**

**រដ្ឋមន្ត្រីក្រសួងពត៌មាន**